**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤៥៧ មស.ក្រ.ខ

**សូមគោរពជូន**
**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ** ៖ ផែនការជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែតនិងឧទ្យានុរក្ស របស់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត សម្រាប់ឆ្នាំ២០១៦។

**យោង** ៖- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ៣០២១ មស.ក្រខ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា រាជរដ្ឋាភិបាល បានអនុញ្ញាតផ្តល់គោលការណ៍ជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិលចំនួន ៧.៦៨៤ កន្លែង មន្ត្រីជាប់កិច្ចសន្យា ចំនួន ៩.៩៦១ នាក់ បុគ្គលិកអណ្តែតចំនួន ៨.៩៥៣ នាក់ និងឧទ្យានុរក្សចំនួន ៩៦០ នាក់ ដើម្បីផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត សម្រាប់ឆ្នាំ២០១៦ ដូចមានបែងចែកតាមចំនួនដូចខាងក្រោម៖

ឯកតា៖នាក់

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌធនធានមនុស្សផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៦ | | | | |
|---|---|---|---|---|---|---|
| | | ក្របខណ្ឌ មន្ត្រីរាជការ | មន្ត្រីជាប់ កិច្ចសន្យា | បុគ្គលិក អណ្តែត | ឧទ្យានុរក្ស | គ្រូបង្រៀនពុទ្ធិក ជាប់កិច្ចសន្យា |
| ១ | ព្រះបរមរាជវាំង | ២៥ | ០ | ២៥០ | | |
| ២ | ទីស្តីការគណៈរដ្ឋមន្ត្រី | ៧៣ | ១៣០ | ០ | | |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១៨ | ១៤ | ៣៨ | | |
| ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ០ | ៩៩ | ៣៦ | | |
| ៥ | មហាផ្ទៃ | ៤៥១ | ៤៥៨ | ៩១០ | | |
| ៦ | ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច | ៣០ | ១២៤ | ១២៦ | | |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ២៦ | ១៣ | ៨៧ | | |
| ៨ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៩០ | ២៦៧ | ២០៨ | | |
| ៩ | ព័ត៌មាន | ៩២ | ៣១៥ | ០ | | |
| ១០ | សុខាភិបាល | ៧៧៥ | ៤.១៩១ | ០ | | |
| ១១ | រ៉ែ និងថាមពល | ៤២ | ១៧៥ | ២៥ | | |
| ១២ | ផែនការ | ៥៣ | ១០៦ | ១៣៥ | | |

| ល.រ | ក្រសួង ស្ថាប័ន | ក្របខណ្ឌធនធានមនុស្សផ្តល់ជូនគ្រប់ក្រសួង ស្ថាប័ន សម្រាប់ឆ្នាំ២០១៦ | | | | |
|---|---|---|---|---|---|---|
| | | ក្របខណ្ឌ មន្ត្រីរាជការ | មន្ត្រីជាប់ កិច្ចសន្យា | បុគ្គលិក អណ្តែត | ឧទ្យានុរក្ស | គ្រូបង្រៀនពុទ្ធិក ជាប់កិច្ចសន្យា |
| ១៣ | ពាណិជ្ជកម្ម | ៨៥ | ១០០ | ៩៦ | | |
| ១៤ | អប់រំ យុវជន និងកីឡា | ៣.៤៨៨ | ១៣៥ | ២៩៦ | | |
| ១៥ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣៣៣ | ១៨២ | ៨៤២ | | |
| ១៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ១១៨ | ២៧៨ | ៥២៩ | | |
| ១៧ | បរិស្ថាន | ៥០ | ១៤៩ | ២២១ | ៩៦០ | |
| ១៨ | អភិវឌ្ឍន៍ជនបទ | ១០៤ | ៤៩ | ៣៨ | | |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៧៧ | ៣៣៩ | ៣៣៤ | | |
| ២០ | ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០២ | ២៩ | ៩៧ | | |
| ២១ | ធម្មការ និងសាសនា | ៣៥ | ៧៨៦ | ០ | | ១.៤៦២ |
| ២២ | កិច្ចការនារី | ៥០ | ៣២២ | ៨៨ | | |
| ២៣ | សាធារណការ និងដឹកជញ្ជូន | ២១៤ | ២២០ | ១.៣៣០ | | |
| ២៤ | យុត្តិធម៌ | ២៨៨ | ៥៥១ | ០ | | |
| ២៥ | ទេសចរណ៍ | ១០០ | ៣១០ | ២១៩ | | |
| ២៦ | រៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ៩៤ | ២០៩ | ៩៦ | | |
| ២៧ | ធនធានទឹក និងឧតុនិយម | ៧៩ | ២១៩ | ២៧០ | | |
| ២៨ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១០៥ | ២៧៣ | ១១០ | | |
| ២៩ | អង្គភាពប្រឆាំងអំពើពុករលួយ | ៥៥ | ១០០ | ៣០ | | |
| ៣០ | មុខងារសាធារណៈ | ១០៩ | ១៤៣ | ៦៤ | | |
| ៣១ | ឧស្សាហកម្ម និងសិប្បកម្ម | ១៧៥ | ១៥០ | ៥០ | | |
| ៣២ | គណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | ៨៥ | ៨៥ | ៥ | | |
| សរុបរួម | | ៧.៦២១ | ១០.៩២១ | ៦.៥៣០ | ៩៦០ | ១.៤៦២ |

ក្រសួងមុខងារសាធារណៈ សូមគោរពជម្រាបជូនគ្រប់ក្រសួង ស្ថាប័ន ដែលទទួលបានសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៨ (ជំនាន់ ឧត្តមគតិជាតិ) សរុបចំនួន ៥៩ នាក់ និងសិស្សមន្ត្រីក្រមការជំនាន់ទី៦ (ជំនាន់ សាមគ្គីភាព) សរុបចំនួន ៥៥ នាក់ ពីសាលាភូមិន្ទរដ្ឋបាលសម្រាប់ឆ្នាំ២០១៦ សូមមេត្តាពិចារណាកាត់ក្របខណ្ឌចេញពីផែនការក្របខណ្ឌឆ្នាំ២០១៦ តាមចំនួនដែលទទួលបានជាក់ស្តែង។

យោងតាមស្មារតីប្រជុំអន្តរក្រសួង ស្ថាប័ន កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ក្រសួងមុខងារសាធារណៈ សូមធ្វើការបែងចែកតួលេខក្របខណ្ឌថ្មីមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងឧទ្យានុរក្សជូនគ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នីមួយៗ ដូចមានក្នុងតារាងឧបសម្ព័ន្ធជាច់ដោយឡែកនៃរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន នីមួយៗ ដូចមានជូនភ្ជាប់មកជាមួយ។

១. ផ្អែកតាមគោលការណ៍ដែលទទួលបានការឯកភាពពីប្រមុខរាជរដ្ឋាភិបាល ការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការសម្រាប់ផែនការក្របខណ្ឌឆ្នាំ២០១៦ នេះ ក្រសួងមុខងារសាធារណៈ សូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា ការប្រឡងប្តូរប្រភេទក្របខណ្ឌមិនត្រូវបានអនុញ្ញាតទេ ប៉ុន្តែដើម្បី (១). បំពេញមុខតំណែងទំនេរ (២). ជម្រុញការពង្រាយមន្ត្រី

រាជការ (៣). ផ្តល់ឱកាសដល់ការអភិវឌ្ឍសមត្ថភាពនិងផ្លាស់ប្តូរអាជីព ដូចនេះ ការប្រឡងក្របខណ្ឌថ្មីត្រូវផ្តល់អាទិភាពដល់មន្ត្រីរាជការដែលមានក្របខណ្ឌស្រាប់។

២. ចំពោះការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត ឧទ្យានុរក្ស និងគ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យាសម្រាប់ផែនការឆ្នាំ២០១៦ គ្រប់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត សូមមេត្តាសហការជាមួយក្រសួងមុខងារសាធារណៈ និងមន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត ដោយអនុវត្តអនុលោមអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងនីតិវិធីជាធរមាន។ ក្នុងករណី មានការប្រែប្រួលចំនួននៃការប្រើប្រាស់បុគ្គលិកអណ្តែតទៅជាមន្ត្រីជាប់កិច្ចសន្យា សូមក្រសួង ស្ថាប័ន មេត្តា ធ្វើសំណើមកក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការស្របតាមតម្រូវការពិតប្រាកដជាក់ស្តែង។

៣. ដោយឡែក ចំពោះការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ របស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ផែនការឆ្នាំ២០១៦ ក្រសួងមុខងារសាធារណៈ នឹងរៀបចំផ្តល់គោលការណ៍ជូនដាច់ដោយឡែក។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តាជ្រាបថា នៅពេលបើកឱ្យមានការប្រឡងប្រជែង សូមមេត្តារៀបចំជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឱ្យចូលបម្រើការងារ ដើម្បីបំពេញមុខតំណែងដែលទំនេរនិងសេចក្តីត្រូវការដែលមានពិតប្រាកដនៅតាមអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងមន្ទីរ អង្គភាពជំនាញ រាជធានី ខេត្ត ព្រមទាំងត្រូវយកចិត្តទុកដាក់ដល់បេក្ខភាពជាជនពិការដែលមានសមត្ថភាពសមស្រប ២% នៃចំនួនក្របខណ្ឌសរុបរបស់សាមីក្រសួង ស្ថាប័ន ហើយត្រូវមានបេក្ខនារីជាប់ជាស្ថាពរពី ២០% ទៅ ៥០% នៃចំនួនក្របខណ្ឌដែលទទួលបានប្រចាំឆ្នាំ។

សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មេត្តារៀបចំស្នើសុំមន្ត្រីតំណាងក្រសួងមុខងារសាធារណៈ ចូលរួមក្នុងដំណើរការប្រឡងឱ្យបានមុនពេលរៀបចំបង្កើតគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសប្រចាំឆ្នាំ ដើម្បីក្រសួងមុខងារសាធារណៈមានលទ្ធភាពចូលរួមសហការចាប់តាំងពីដំណាក់កាលដំបូង។

សូម សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- -សាលារាជធានី ខេត្ត
- -នាយកដ្ឋានគ្រប់គ្រងក្របខ័ណ្ឌនៃក្រសួងមុខងារសាធារណៈ
- -មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត
  " ដើម្បីសហការអនុវត្ត "
- -ឯកសារ កាលប្បវត្តិ